វិទ្យាស្ថានសភាកម្ពុជា
PARLIAMENTARY INSTITUTE OF CAMBODIA
STRENGTHENING PARLIAMENTARY CAPACITY

# ឯកសារស្រាវជ្រាវសង្ខេប

គណៈកម្មការទី៦ រដ្ឋសភា

# ថវិការបស់សាលាដំបូង
# នៃខេត្តមណ្ឌលគិរី និងខេត្តត្បូងឃ្មុំ


| | | |
|---|---|---|
| អ្នកនិពន្ធ៖ | លោក **មូសារ អ៊ីស្សាម** | ប្រធានផ្នែកស្រាវជ្រាវ (វ.ស.ក) |
| | លោក **លី យ៉ាសាក់** | ប្រធានក្រុម (វ.ស.ក) |
| | កញ្ញា **សេន ចន្ទី** | មន្ត្រីអគ្គលេខាធិការដ្ឋាន (ព្រឹទ្ធសភា) |
| | កញ្ញា **វង្ស ចន្ទរស្មីដារា** | មន្ត្រីអគ្គលេខាធិការដ្ឋាន (ព្រឹទ្ធសភា) |



ខែសីហា ឆ្នាំ២០១៩

# កំណត់សម្គាល់

វិទ្យាស្ថានសភាកម្ពុជា(វ.ស.ក) គឺជាស្ថាប័នឯករាជ្យមួយដែលផ្តល់ការគាំទ្រដល់សភាកម្ពុជា តាមរយៈការ ផ្តល់នូវឯកសារស្រាវជ្រាវតបតាមសំណើរបស់សមាជិក សមាជិកា និងគណៈកម្មការជំនាញរបស់រដ្ឋសភា ព្រឹទ្ធសភា ដែលមានការវិភាគទៅលើបញ្ហាដែលកំពុងតែកើតមាននៅពេលបច្ចុប្បន្ន និងដែលអាចនឹងកើតឡើងនាពេលអនាគតលើប្រធានបទការរៀបចំច្បាប់ និងគោលនយោបាយសាធារណៈ។ ឯកសារនេះផ្តល់នូវព័ត៌មានដែលពាក់ព័ន្ធនឹងការងារសភា និងការងារមណ្ឌល ឬភូមិភាគរបស់សមាជិក-សមាជិកាសភា ក៏ប៉ុន្តែរាល់អត្ថន័យដែលមាននៅក្នុងឯកសារទាំងនេះមិនមែនតំណាង ឬឆ្លុះបញ្ចាំងអំពីទស្សនៈផ្ទាល់របស់វិទ្យាស្ថានសភាកម្ពុជា សភា ឬសមាជិក-សមាជិកាណាម្នាក់នោះឡើយ ។

ខ្លឹមសារនៃឯកសារនេះមានកំណត់កាលបរិច្ឆេទច្បាស់លាស់ ដើម្បីផ្តល់ជាឯកសារជំនួយស្មារតីតបតាមម្ចាស់សំណើ ។ ឯកសារនេះមិនមានគោលបំណងផ្តល់ប្រឹក្សាផ្នែកច្បាប់ ឬគោលនយោបាយណាមួយឡើយ ដោយផ្តោតតែលើព័ត៌មានពីឯកសារដែលមានស្រាប់ និងមិនបានសិក្សាឱ្យ គ្រប់ជ្រុងជ្រោយដើម្បីឆ្លើយតបទៅនឹងបញ្ហាលម្អិតនៃការស្រាវជ្រាវសង្ខេបនោះទេ ពោលគឺដើម្បីឆ្លើយតបទៅនឹងសំណើដែលទទួលបានតែប៉ុណ្ណោះ។

ខ្លឹមសារនៃឯកសារស្រាវជ្រាវសង្ខេបនេះ ស្ថិតក្រោមច្បាប់ជាធរមានរបស់កម្ពុជា និងកិច្ចព្រមព្រៀងអន្តរជាតិស្តីពីសិទ្ធិអ្នកនិពន្ធ។ រាល់ការរៀបចំចងក្រងឡើងវិញដោយដកស្រង់នូវផ្នែកណាមួយ ឬខ្លឹមសារទាំងស្រុងនៃឯកសារស្រាវជ្រាវនេះ ត្រូវមានការអនុញ្ញាតពីវិទ្យាស្ថានសភាកម្ពុជា។

©រក្សាសិទ្ធិ ឆ្នាំ២០១៩ វិទ្យាស្ថានសភាកម្ពុជា (វ.ស.ក)។

# មាតិកា


តារាង ........................................ ii
រូបភាព ........................................ ii
១. សេចក្ដីផ្ដើម ........................................ 1
២. ក្រមខណ្ឌច្បាប់ ........................................ 1
៣. ថវិកាចំណាយទៅលើវិស័យយុត្តិធម៌ ........................................ 2
៤. ថវិកាសម្រាប់សាលាដំបូងក្នុងខេត្តត្បូងឃ្មុំ និងខេត្តមណ្ឌលគីរី ........................................ 3
៥. ចំណាយថវិកាសម្រាប់មនុស្សម្នាក់ៗនៅតាមសាលាដំបូងរាជធានី-ខេត្ត ........................................ 4
៦. ការបែងចែកថវិកាចំណាយរបស់សាលាដំបូងខេត្តត្បូងឃ្មុំ និងខេត្តមណ្ឌលគីរី ........................................ 6
៧. សេចក្ដីសន្និដ្ឋាន ........................................ 6
ឯកសារយោង ........................................ 8

# តារាង


តារាង១៖ ចំណែកនៃចំណាយតាមស្ថាប័ន/ប្រភេទ ក្នុងវិស័យយុត្តិធម៌ .................................... 3

តារាង២៖ ចំណាយថវិកាសម្រាប់សាលាដំបូងរាជធានី ខេត្ត ក្នុងខេត្តត្បូងឃ្មុំ និងខេត្ត មណ្ឌលគីរី... 4


# រូបភាព


រូបភាព១៖ ចំណាយថវិកាសម្រាប់មនុស្សម្នាក់ៗនៃចំណាយថវិកាសាលាដំបូងរាជធានី ខេត្តឆ្នាំ២០១៩ ........................................................................................ 5

រូបភាព២៖ ចំណែកនៃចំណាយនៅសាលាដំបូងខេត្ត ត្បូងឃ្មុំ និងខេត្តមណ្ឌគីរី ........................... 6

## ១. សេចក្តីផ្តើម

ដើម្បីរៀបចំបេសកកម្មទៅខេត្តមណ្ឌលគីរី និងខេត្តត្បូងឃ្មុំ ពីថ្ងៃទី០៦ ដល់ថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៩ គណៈកម្មការទី៦ នៃរដ្ឋសភា បានស្នើសុំឱ្យវិទ្យាស្ថានសភាកម្ពុជាសិក្សាស្រាវជ្រាវអំពីថវិការបស់សាលាដំបូងនៃនៃខេត្តទាំងពីរនេះ។

សមាជិកគណៈកម្មការតែងមានចម្ងល់មួយចំនួនទាក់ទងនឹងបញ្ហាថវិការបស់តុលាការ អយ្យការអមតុលាការ និងរដ្ឋបាលតុលាការ នៅតាមបណ្តាខេត្តដែលសមាជិកគណៈកម្មការបានចុះទៅបំពេញបេសកកម្មកន្លងមក។ ដូច្នេះព័ត៌មានអំពីថវិកាក្នុងវិស័យនេះនឹងជួយដោះស្រាយចម្ងល់របស់សមាជិកគណៈកម្មការ ក៏ដូចជាអាចជួយជាជំនួយស្មារតីដល់គណៈកម្មការ ក្នុងការឆ្លើយតបទៅនឹងសំណួរ ឬការព្រួយបារម្ភរបស់រដ្ឋបាលមូលដ្ឋានក្នុងអំឡុងពេលបេសកកម្មខាងមុខនេះ ។

ការសិក្សានេះមានគោលបំណងជួយគាំទ្រដល់គណៈកម្មការតាមរយៈការផ្តល់ព័ត៌មានឱ្យបានច្រើនតាមដែលអាចធ្វើទៅបាន ដើម្បីដោះស្រាយនូវសំណួរស្រាវជ្រាវចំនួនបីនៅខាងក្រោម ហើយដើម្បីជម្រាបជូនគណៈកម្មការថា តើទិន្នន័យព័ត៌មានណាខ្លះដែលគណៈកម្មការត្រូវការ និងមិនអាចរកបាន។ ដូច្នេះប្រសិនបើចាំបាច់ និងស្របទៅតាមនីតិវិធីរបស់រដ្ឋសភា គណៈកម្មការ អាចធ្វើការស្នើសុំបន្ត ទៅស្ថាប័នដែលមានសមត្ថកិច្ច ដើម្បីទទួលបានការបញ្ជាក់បន្ថែម៖

- តើអ្វីទៅជាក្របខ័ណ្ឌច្បាប់សម្រាប់ផ្តល់ហិរញ្ញប្បទានដល់សាលាដំបូង និងអយ្យការអមសាលាដំបូងនៅក្នុងខេត្តមណ្ឌលគីរី និងខេត្តត្បូងឃ្មុំ?
- តើការបែងចែក និងការផ្តល់ថវិកាជាក់ស្តែងទៅសាលាដំបូង និងអយ្យការអមសាលាដំបូង នៃខេត្តទាំងពីរមានស្ថានភាពយ៉ាងដូចម្តេចដែរ?
- តើថវិកាទាំងនោះគ្រប់គ្រាន់សម្រាប់បំពេញការងាររបស់ពួកគាត់ដែរឬទេ?

## ២. ក្រមខ័ណ្ឌច្បាប់

មាត្រា ៧៩ នៃច្បាប់ស្តីពី ការរៀបចំអង្គការតុលាការ ប្រកាសឱ្យប្រើនៅថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤[1] លើកឡើងថា « សាលាដំបូង និងអយ្យការអមសាលាដំបូង សាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍ ព្រមទាំងតុលាការកំពូល និងមហាអយ្យការអមតុលារការកំពូល មានកញ្ចប់ថវិកាដោយឡែក សម្រាប់ដំណើរការ ដែលបានវិភាជន៍ពីកញ្ចប់ថវិការបស់ក្រសួងយុត្តិធម៌ »។

ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩[2] បានបង្ហាញថាថវិការបស់វិស័យយុត្តិធម៌ត្រូវបានវិភាជន៍ដល់ក្រសួងយុត្តិធម៌ តុលាការកំពូល សាលាឧទ្ធរណ៍ ឧត្តមក្រុមប្រឹក្សាអង្គចៅក្រម និងមន្ទីរជំនាញរាជធានី-ខេត្ត។ មន្ទីរជំនាញរាជធានី-ខេត្តនោះ អាចជាលេខាធិដ្ឋានរដ្ឋបាលនៃសាលាដំបូងរាជធានី-ខេត្ត។

កញ្ចប់ថវិកានេះត្រូវបានវិភាជន៍ទៅគ្រប់សាលាដំបូង និងអយ្យការអមសាលាដំបូង តែមិនមានព័ត៌មានលម្អិតនៃការបែងចែកថវិកាទៅសាលាដំបូង និងអយ្យការអមសាលាដំបូងនៅតាមរាជធានី-ខេត្ត នីមួយៗ សំរាប់ការសិក្សានេះឡើយ។

មានអនុក្រឹត្យចំនួនបី ចុះថ្ងៃទី ៤ ខែ កុម្ភៈ ឆ្នាំ ២០១៦ ទាក់ទងទៅនឹងការរៀបចំ និងការប្រព្រឹត្តទៅនៃលេខាធិការដ្ឋានរដ្ឋបាលនៃសាលាដំបូង សាលាឧទ្ធរណ៍ និងតុលាការកំពូល បានបង្ហាញថា លេខាធិការដ្ឋានរដ្ឋបាលនៃតុលាការទាំងនេះមានសមត្ថកិច្ចលើតុលាការ និងអយ្យការអម ទាក់ទងនឹងរដ្ឋបាល ទាំងធនធានមនុស្ស និងហិរញ្ញវត្ថុ ដែលអនុលោមតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិដែលចូលជាធរមាន[1]។

មាត្រា ៧៩ នៃច្បាប់ស្តីពី ការរៀបចំអង្គការតុលាការ ឆ្នាំ២០១៤ បានចែងថា ប្រធានតុលាការគ្រប់ជាន់ថ្នាក់ជាអាណាប័កផ្ទេរសិទ្ធិពីរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ សម្រាប់រដ្ឋបាល និងការចាត់ចែងថវិកាតុលាការ និងអយ្យការអមតុលាការទាំងនេះដោយអនុលោមតាមមាត្រា ១២៨ ថ្មីនៃរដ្ឋធម្មនុញ្ញ (ឯករាជ្យភាពនៃអំណាចតុលាការ)។ បទបញ្ញត្តិដដែលនេះក៏បានចែងថា ត្រូវមានអនុក្រឹត្យមួយសម្រាប់ការគ្រប់គ្រង និងការចាត់ចែងថវិការបស់តុលាការ និងអយ្យការ។ ប៉ុន្តែអនុក្រឹត្យនេះមិនទាន់មាននៅឡើយទេ។

## ៣. ថវិកាចំណាយទៅលើវិស័យយុត្តិធម៌

ផ្នែកនេះនឹងពិនិត្យពីស្ថានភាពចំណាយលើវិស័យយុត្តិធម៌នៅក្នុងប្រទេសកម្ពុជា ព្រមទាំងពិនិត្យទៅលើស្ថានភាពចំណាយរបស់សាលាដំបូងនៅក្នុងខេត្តមណ្ឌលគីរី និងខេត្តត្បូងឃ្មុំ។

ក្រសួងយុត្តិធម៌ផ្តល់ថវិកាដល់ប្រព័ន្ធតុលាការទាំងបីថ្នាក់ ដើម្បីអោយតុលាការទាំងបីថ្នាក់នោះគ្រប់គ្រងចាត់ចែងដោយផ្ទាល់[1]។ តារាង១ បង្ហាញថា ចំណាយសរុបសម្រាប់វិស័យយុត្តិធម៌បានកើនឡើងគួរឲ្យកត់សម្គាល់ក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះពី ៦៦ ០៤៨លានរៀល ក្នុងឆ្នាំ២០១៥ ទៅដល់ ១៥៧ ៣២៧លានរៀល ក្នុងឆ្នាំ២០១៩ កើនឡើង ២៤ភាគរយជាមធ្យមប្រចាំឆ្នាំ។ ការចំណាយថវិកាជាតិសរុបមានការកើនឡើងប្រមាណ ១៥ភាគរយ ប្រចាំឆ្នាំក្នុងអំឡុងពេលដូចគ្នា។ រីឯការចំណាយដែលបានបែងចែកទៅលើវិស័យយុត្តិធម៌ធៀបនឹងចំណាយថ្នាក់ជាតិសរុបមានការកើនឡើងពី ០,៤៥ភាគរយ ដល់ ០,៦១ភាគរយ។ ចំណាយសរុបលើវិស័យយុត្តិធម៌បានបែងចែកអោយសាលាដំបូងរាជធានី-ខេត្ត ប្រមាណជា ៥០ភាគរយជាមធ្យម ខណៈដែលសាលា

[1] ឧទាហរណ៍ មាត្រា៤ នៃអនុក្រឹត្យលេខ ២១ អនក្រ/បក ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃលេខាធិការដ្ឋានរដ្ឋបាលនៃសាលាដំបូង ចុះថ្ងៃទី ០៤ ខែកុម្ភៈ ឆ្នាំ២០១៦ (សូមមើលឧបសម្ព័ន្ធ)

ឧទ្ធរណ៍ទទួលបាន ៦ភាគរយ តុលាការកំពូលទទួលបាន ៥ភាគរយ និងឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមទទួលបាន ៤ភាគរយ។ ចំណែកថវិកាដែលនៅសល់ត្រូវចំណាយដោយក្រសួងយុត្តិធម៌។

### តារាង១៖ ចំណែកនៃចំណាយថវិកាតាមស្ថាប័ន/ប្រភេទ ក្នុងវិស័យយុត្តិធម៌

| ការចំណាយ | អនុវត្តន៍ | | | ច្បាប់ | | មធ្យម |
|---|---|---|---|---|---|---|
| | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | ២០១៩ | |
| ថវិកាសរុបសម្រាប់វិស័យយុត្តិធម៌ (គិតជាលានរៀល) | ៦៦ ០៤៨ | ១០៣ ៩៧៤ | ១១២ ៦៩៨ | ១៤៧ ៥៦៦ | ១៥៧ ៣២៧ | |
| កំណើនប្រចាំឆ្នាំ | | ៥៧% | | ៣១% | ៧% | ២៤% |
| ក្រសួងយុត្តិធម៌ | ៣៦% | ២៦% | ២៨% | ២៩% | ៣១% | ៣០% |
| ឧត្តមក្រុមប្រឹក្សាអង្គចៅក្រម | ៦% | ៤% | ៤% | ៤% | ៤% | ៤% |
| តុលាការកំពូល | ៥% | ៥% | ៥% | ៥% | ៥% | ៥% |
| សាលាឧទ្ធរណ៍ | ៦% | ៦% | ៦% | ៥% | ៥% | ៦% |
| មន្ទីរជំនាញរាជធានី-ខេត្ត[2] | ៤៥% | ៤៤% | ៥៤% | ៥១% | ៥១% | ៤៩% |
| ចំណាយមូលធន | ៣% | ១៥% | ២% | ៦% | ៤% | ៦% |
| ចំណាយជាតិសរុប | ១៤៦៦០១៤៧ | ១៦៩២៧៥៤៥ | ២០០១៦០០៧ | ២៣៤២៨២៩៨ | ២៥៧៥៨០២៨ | |
| កំណើនប្រចាំឆ្នាំ | | ១៥% | ១៨% | ១៧% | ១០% | ១៥% |
| ចំណែកនៃវិស័យយុត្តិធម៌ធៀបនឹងចំណាយថវិកាជាតិសរុប | ០,៤៥% | ០,៦១% | ០,៥៦% | ០,៦៣% | ០,៦១% | ០,៥៧ % |

*ប្រភព៖ ច្បាប់ទូទាត់ថវិកាឆ្នាំ ២០១៥-២០១៧ និងច្បាប់ថវិកាជាតិឆ្នាំ២០១៨-២០១៩[2, 3]*

## ៤. ថវិកាសម្រាប់សាលាដំបូងក្នុងខេត្តត្បូងឃ្មុំ និងខេត្តមណ្ឌលគីរី

កំណើននៃចំណាយថវិកាថ្នាក់ជាតិសម្រាប់សាលាដំបូងខេត្តត្បូងឃ្មុំមានការកើនឡើងយ៉ាងឆាប់រហ័សជាងកំណើននៃចំណាយថវិកាសម្រាប់សាលាដំបូងរាជធានី-ខេត្តគឺ ៤៤ ភាគរយប្រចាំឆ្នាំ ធៀបទៅនឹងកំណើនចំណាយថវិកាសរុបរបស់សាលាដំបូងរាជធានី-ខេត្ត ដែលមានអត្រាកំណើនត្រឹមតែ ២៨ភាគរយជាមធ្យមប្រចាំតែប៉ុណ្ណោះពីឆ្នាំ

[22] មន្ទីរជំនាញរាជធានី-ខេត្តនោះ អាចជាលេខាធិដ្ឋានរដ្ឋបាលនៃសាលាដំបូងរាជធានី-ខេត្ត។

២០១៦ ដល់ឆ្នាំ ២០១៩។ ចំណែកនៃចំណាយរបស់សាលាដំបូងខេត្តត្បូងឃ្មុំធៀបនឹងចំណាយសរុបរបស់សាលាដំបូងរាជធានី-ខេត្តកើនពី ២,៦ភាគរយ ទៅ ៤,៥ភាគរយ ក្នុងរយៈពេលដូចគ្នា។

ក្នុងរយៈពេលបីឆ្នាំចុងក្រោយនេះចំណាយថវិកាថ្នាក់ជាតិសម្រាប់សាលាដំបូងខេត្តមណ្ឌលគីរីមានកំណើនប្រហាក់ប្រហែលនឹងកំណើនថវិកាចំណាយសរុបរបស់សាលាដំបូងរាជធានី-ខេត្ត ប៉ុន្តែឆ្នាំ២០១៩ មានការធ្លាក់ចុះ ៦ភាគរយ។ ចំណែកនៃចំណាយថវិកាសម្រាប់សាលាដំបូងខេត្តមណ្ឌលគីរីធៀបនឹងចំណាយថវិកាសរុបរបស់សាលាដំបូងរាជធានី-ខេត្ត មានអត្រាថេរ ២,៧ភាគរយជាមធ្យម ប៉ុន្តែការព្យាករណ៍ធ្លាក់ចុះមកត្រឹម ២,៤ភាគរយក្នុងឆ្នាំ២០១៩។

**តារាង២៖ ចំណាយថវិកាសម្រាប់សាលាដំបូងរាជធានី-ខេត្ត នៅខេត្តត្បូងឃ្មុំ និងខេត្តមណ្ឌលគីរី**

| ចំណាយថវិកា | | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | ២០១៩ | គិតជាមធ្យម |
|---|---|---|---|---|---|---|---|
| សាលាដំបូងរាជធានីខេត្ត (១) | ចំណាយសរុប | ២៩ ៥២៤ | ៤៥ ៦៩៩ | ៦១ ១៦៥ | ៧៥ ២២៧ | ៧៩ ៩៥៩ | - |
| | កំណើនពីមួយឆ្នាំទៅមួយឆ្នាំ | - | ៥៥% | ៣៤% | ២៣% | ៦% | ២៨% |
| ខេត្តត្បូងឃ្មុំ | ចំណាយថវិកាសម្រាប់សាលាដំបូងខេត្តត្បូងឃ្មុំ (២) | គ្មាន | ១ ១៨៧ | ១ ៩២៩ | ៣ ១៥០ | ៣ ៥៨០ | - |
| | កំណើនពីមួយឆ្នាំទៅមួយឆ្នាំ | គ្មាន | - | ៦៣% | ៦៣% | ១៤% | ៤៤% |
| | ចំណែកនៃថវិកាសាលាដំបូងខេត្តត្បូងឃ្មុំ ធៀបនឹងសរុបសាលាដំបូងរាជធានី-ខេត្ត (២/១) | គ្មាន | ២,៦% | ៣,២% | ៤,២% | ៤,៥% | ៣,៦% |
| ខេត្តមណ្ឌលគីរី | ចំណាយថវិកាសម្រាប់សាលាដំបូងខេត្តមណ្ឌលគីរី (៣) | ៩០១ | ១ ២៦០ | ១ ៦៤៧ | ២ ០៣៣ | ១ ៩០៣ | - |
| | កំណើនពីមួយឆ្នាំទៅមួយឆ្នាំ | - | ៤០% | ៣១% | ២៣% | -៦% | ២១% |
| | ចំណែកនៃថវិកាសាលាដំបូងខេត្តមណ្ឌលគីរីធៀបនឹងចំណាយសរុបសាលាដំបូងរាជធានី-ខេត្ត (៣/១) | ៣,១% | ២,៨% | ២,៧% | ២,៧% | ២,៤% | ២,៧% |

*ប្រភព៖ ច្បាប់ថវិកាជាតិ ឆ្នាំ២០១៥-២០១៩[4]*

## ៥. ចំណាយថវិកាសម្រាប់មនុស្សម្នាក់ៗនៅតាមសាលាដំបូងរាជធានី-ខេត្ត

រូបភាព១ ខាងក្រោមបង្ហាញពីការប្រៀបធៀបចំណាយថវិកាសម្រាប់មនុស្សម្នាក់ៗរបស់សាលាដំបូងរាជធានី-ខេត្តទូទាំងប្រទេស។ ក្នុងចំណោមខេត្តទាំងអស់ ខេត្តកែបពុំទាន់មានសាលាដំបូងខេត្តនោះទេ ។ ការចំណាយថវិកាសម្រាប់មនុស្សម្នាក់ៗរបស់សាលាដំបូងខេត្តត្បូងឃ្មុំមានកម្រិតទាបជាងគេក្នុងចំណោមសាលាដំបូងរាជធានី-ខេត្តទូទាំងប្រទេស ដែលមានចំនួនតែ ៤០៦ រៀលប៉ុណ្ណោះ បន្ទាប់ពីខេត្តតាកែវ ដែលទទួលបាន ២០៩៣ រៀល ។ ក្នុងរយៈ

ពេលបួនឆ្នាំចុងក្រោយនេះ កំណើនចំណាយថវិការបស់សាលាដំបូងខេត្តត្បូងឃ្មុំខ្ពស់ អាចជាកិច្ចប្រឹងប្រែង ដើម្បីអោយចំណាយថវិកាសម្រាប់មនុស្សម្នាក់ៗមានការកើនឡើងប្រហាក់ប្រហែលនឹងខេត្តដ៏ទៃទៀត។

ចំណាយថវិកាសម្រាប់មនុស្សម្នាក់ៗរបស់សាលាដំបូងខេត្តមណ្ឌលគីរីស្ថិតនៅខ្ពស់លំដាប់ទី២ ដែលមានចំនួន ២៤ ៤១៤រៀល។ កំណើនចំណាយរបស់សាលាដំបូងខេត្តមណ្ឌលគីរីប្រហាក់ប្រហែលទៅនឹងកំណើនចំណាយថវិកាសរុបរបស់សាលាដំបូងរាជធានី-ខេត្ត ហើយការធ្លាក់ចុះចំណាយថវិកាសម្រាប់សាលាដំបូងខេត្តមណ្ឌលគីរីក្នុងឆ្នាំ ២០១៩ អាចឆ្លុះបញ្ចាំងពីការចំណាយថវិកាសម្រាប់មនុស្សម្នាក់ៗរបស់សាលាដំបូងខេត្តមណ្ឌលគីរីមានកម្រិតខ្ពស់ស្រាប់ហើយ។
ម៉្យាងទៀត ភាពខុសគ្នានៃការចំណាយសម្រាប់មនុស្សម្នាក់ៗនៃថវិកាសាលាដំបូង អាចបណ្តាលមកពីចំនួនករណីជម្លោះ និងបទឧក្រិដ្ឋសម្រាប់មនុស្សម្នាក់ៗក្នុងខេត្តនីមួយៗ តែវិទ្យាស្ថានសភាកម្ពុជាមិនអាចរកទិន្នន័យនេះបានឡើយ។

## រូបភាព១៖ ចំណាយថវិកាសម្រាប់មនុស្សម្នាក់ៗនៃចំណាយថវិកាសាលាដំបូងរាជធានី ខេត្តឆ្នាំ២០១៩




*ប្រភព៖ច្បាប់ថវិកាជាតិ ឆ្នាំ ២០១៩ និង ក្រសួងមហាផ្ទៃ និងទិន្នន័យប្រជាសាស្ត្រ ឆ្នាំ ២០១៤នៃក្រសួងផែនការ[5, 6]*

## ៦. ការបែងចែកថវិកាចំណាយរបស់សាលាដំបូងខេត្តត្បូងឃ្មុំ និងខេត្តមណ្ឌលគិរី

រូបភាព៧ បង្ហាញថាចំណែកនៃការចំណាយធំបំផុតរបស់សាលាដំបូងខេត្តទាំងពីរ គឺចំណាយទៅលើបន្ទុកបុគ្គលិក ដែលមានចំនួនជាមធ្យមប្រមាណ ៥២ ភាគរយ ក្នុងខេត្តត្បូងឃ្មុំ និង ៥៤ភាគរយ ក្នុងខេត្តមណ្ឌលគីរី។ ចំណែកនៃការចំណាយលំដាប់ទី២ គឺសាលាដំបូងខេត្តបានចំណាយទៅលើផ្នែកសេវាកម្មផ្សេងៗ ដែលជាមធ្យមមានចំនួន ៣៣ភាគរយ សម្រាប់ខេត្តត្បូងឃ្មុំ និង២៨ភាគរយ សម្រាប់ខេត្ត មណ្ឌលគិរី ក្នុងរយៈពេលដូចគ្នា។ ចំណាយដែលនៅសល់គឺជាចំណាយសម្រាប់ទិញសម្ភារៈផ្សេងៗ។

ខេត្តទាំង២បានចំណាយថវិកាខ្ពស់លើការទិញសម្ភារៈ និងសេវា (ប្រមាណ ៤៥ ភាគរយ ទៅ ៥០ ភាគរយ ធៀបនឹងការចំណាយផ្នែកនេះសម្រាប់សាលាដំបូងរាជធានី-ខេត្តទូទាំងប្រទេសដែលមានប្រមាណ ៤០ ភាគរយ)។ តំណាងរាស្ត្រអាចចោទជាសំណួរហេតុអ្វីបានជាមានការចំណាយថវិកាខ្ពស់ខ្លាំងលើបន្ទុកបុគ្គលិក។

មិនមានភាពខុសប្លែកគ្នាច្រើនលើសមាមាត្រចំណាយលើបន្ទុកបុគ្គលិក នៅក្នុងសាលាដំបូងខេត្តទាំង២ ពុំ ប៉ុន្តែសមាជិកសភាអាចសួរសំណួរបន្តទៀតថា ហេតុអ្វីបានជាខេត្តមណ្ឌលគិរី ចំណាយលើការទិញសម្ភារៈ និងសេវាកម្មលើសមាមាត្រមួយដែលមានតុល្យភាព ខណៈដែលខេត្តត្បូងឃ្មុំ ហាក់ដូចជាចំណាយថវិកាច្រើនទៅលើសេវាកម្មក្នុងរយៈពេលប៉ុន្មានឆ្នាំ។

ការចំណាយលើវិស័យយុត្តិធម៌មិនបានបញ្ចូលកញ្ចប់ថវិកាសម្រាប់កម្មវិធីសង្គមដើម្បីជួយគាំទ្រប្រជាពលរដ្ឋដែលមានចំណូលទាបក្នុងការទទួលបានសេវាផ្នែកច្បាប់ ដូចករណីដែលមន្ទីរអប់រំ យុវជន និងកីឡា និងមន្ទីរសុខាភិបាលដែលមានកញ្ចប់ថវិកានេះ។ តំណាងរាស្ត្រអាចចោទសួរថាតើកញ្ចប់ថវិកាផ្នែកនេះគួរតែត្រូវបានពិចារណាឬអត់នៅថ្ងៃខាងមុខ។

**រូបភាព៧៖ ចំណែកនៃចំណាយនៅសាលាដំបូងខេត្ត ត្បូងឃ្មុំ និងខេត្តមណ្ឌគិរី**




*ប្រភព៖ច្បាប់ថវិកាជាតិ ឆ្នាំ ២០១៥-២០១៨[4]*

## ៧. សេចក្តីសន្និដ្ឋាន

ការចំណាយថវិកាជាតិសម្រាប់សាលាដំបូងខេត្តត្បូងឃ្មុំ បានកើនឡើងលើសកំណើនការចំណាយ ថវិកាសរុបរាជធានី-ខេត្ត ក្នុងរយៈពេល៤ឆ្នាំចុងក្រោយ ប៉ុន្តែចំណាយថវិកាសម្រាប់មនុស្សម្នាក់ៗនៅខេត្តនេះមានចំនួនតិចជាងគេនៅទូទាំងប្រទេស។

ការចំណាយថវិកាជាតិសម្រាប់សាលាដំបូងខេត្តមណ្ឌលគីរី មានកំណើនប្រហាក់ប្រហែលទៅនឹងកំណើននៃចំណាយថវិកាសរុបរាជធានី-ខេត្ត ក្នុងរយៈពេល៣ឆ្នាំចុងក្រោយនេះ ប៉ុន្តែថវិកាចំណាយសម្រាប់ឆ្នាំ២០១៩ រំពឹងថានឹងមានការធ្លាក់ចុះ។ ការចំណាយថវិកាសម្រាប់មនុស្សម្នាក់ៗនៅខេត្តនេះគឺស្ថិតនៅខ្ពស់លំដាប់ទី២ ក្នុងព្រះរាជាណាចក្រកម្ពុជា។

ខេត្តទាំង២បានចំណាយថវិកាខ្ពស់លើការទិញសម្ភារៈ និងសេវា (ប្រមាណ ៤៥ ភាគរយ ទៅ ៥០ ភាគរយ ធៀបនឹងការចំណាយការចំណាយផ្នែកនេះសម្រាប់សាលាដំបូងរាជធានី ខេត្តទូទាំងប្រទេសដែលមានប្រមាណ ៤០ ភាគរយ។ តំណាងរាស្ត្រអាចចោទជាសំណួរហេតុអ្វីបានជាមានការចំណាយថវិកាខ្ពស់ខ្លាំងលើបន្ទុកបុគ្គលិក។

មិនមានភាពខុសប្លែកគ្នាច្រើនលើសមាមាត្រចំណាយលើបន្ទុកបុគ្គលិក នៅក្នុងសាលាដំបូងខេត្តទាំង២ ប៉ុន្តែសមាជិកសភាអាចសួរសំណួរបន្តទៀតថា ហេតុអ្វីបានជាខេត្តមណ្ឌលគីរី ចំណាយលើការទិញសម្ភារៈ និងសេវាកម្មលើសមាមាត្រមួយដែលមានតុល្យភាព ខណៈដែលខេត្តត្បូងឃ្មុំ ហាក់ដូចជាចំណាយថវិកាច្រើនទៅលើសេវាកម្មក្នុងរយៈពេលប៉ុន្មានឆ្នាំ។

ការចំណាយលើវិស័យយុត្តិធម៌មិនបានបញ្ចូលកញ្ចប់ថវិកាសម្រាប់កម្មវិធីសង្គមដើម្បីជួយគាំទ្រប្រជាពលរដ្ឋដែលមានចំណូលទាបក្នុងការទទួលបានសេវាផ្នែកច្បាប់ ដូចករណីដែលមន្ទីរអប់រំ យុវជន និងកីឡា និងមន្ទីរសុខាភិបាលដែលកញ្ចប់ថវិកានេះ។ តំណាងរាស្ត្រអាចចោទសួរថាតើកញ្ចប់ថវិកាផ្នែកនេះគួរតែត្រូវបានពិចារណាឬអត់នៅថ្ងៃខាងមុខ។

នេះក៏មានប្រយោជន៍ផងដែរក្នុងការយល់ដឹងពីមូលដ្ឋាន ដែលប្រធានតុលាការ ក្នុងការស្នើសុំថវិកា ដែលបានធ្វើឡើងកាលពីឆ្នាំមុន ដើម្បីកំណត់ថាតើកញ្ចប់ថវិកានេះ ឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ប្រជាជន មន្ត្រីយុត្តិធម៌ និងមន្ត្រីតុលាការ ដែលទទួលខុសត្រូវក្នុងការអនុវត្តច្បាប់។ ការចុះបេសកម្មសិក្សាទៅបណ្តាខេត្តរបស់គណៈកម្មាធិការ ៦ អាចជួយប្រមូលព័ត៌មាននេះពីអ្នកពាក់ព័ន្ធនានា ដើម្បីវាយតម្លៃតម្រូវការរបស់បុគ្គល មន្ត្រីយុត្តិធម៌ និងមន្ត្រីតុលាការ ដើម្បីទទួលគុណភាពខ្ពស់ សមធម៌ និងប្រសិទ្ធភាពក្នុងការវិភាជថវិកា។

# ឯកសារយោង


1. *Law on the organization of the courts NS/RKM/2014/015 promulgated on 16 July 2014*. Phnom Penh, Cambodia: Available at: http://sithi.org/admin/upload/law/law-on-the-org-of-the-courts-kh.pdf [Accessed 29/07/2019].
2. *Finance Law 2019 NS/RKM/2018/017 promulgated on 12 December 2018*.
3. MoEF, (2015-2017). *Budget implemnetation* Phnom Penh, Cambodia: Ministry of Economy and Finance, Available at: https://www.mef.gov.kh/tofe.html [Accessed 29/07/2019].
4. MoEF, (2017-2019). *National Budget Law*. Phnom Penh, Cambodia: Ministry of Economy and Finance, Available at: https://www.mef.gov.kh/tofe.html [Accessed 29/07/2019].
5. MoEF, (2015-2019). *National Budget law*. phnom Phnom, Cambodia: Ministry of Economy and Finance, Available at: https://www.mef.gov.kh/tofe.html [Accessed 29/07/2019].
6. NIS. (.n.y.). *Commune data base* [Online]. Phnom Penh, Cambodia: National Institute of Statistics. Available at: https://www.nis.gov.kh/index.php/en/national-statistical-systems/official-statistics-of-cambodia [Accessed 19 July 2019].
7. MoEF, (2019). *National budget law*. Phnom Penh, Cambodia: Ministry of Economy and Finance, Available at: https://www.mef.gov.kh/tofe.html [Accessed 29/07/2019].